00212359

C26/I/27

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គបុរេជំនុំជម្រះ
PRE-TRIAL CHAMBER
CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៤)

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 15 / 08 / 08
ម៉ោង (Time/Heure): 14:10
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

នៅចំពោះមុខ: ចៅក្រម ប្រាក់ គឹមសាន ប្រធាន
ចៅក្រម Rowan DOWNING
ចៅក្រម នេ៎យ ថុល
ចៅក្រម Katinka LAHUIS
ចៅក្រម ហួត វុទ្ធី

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 15 / 08 / 08
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: C.A. FRY

កាលបរិច្ឆេទ: ១៥ សីហា ឆ្នាំ ២០០៨

---

សាធារណៈ:

**សេចក្តីបង្គាប់ដល់មេធាវីការពារក្តីស្តីពីបណ្តឹងឧទ្ធរណ៍**
**ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង

Robert PETIT

ពេជ្រ សម្បត្តិ

Alex BATES

**ជនត្រូវចោទ**

ខៀវ សំផន

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

លោក ហុង គីមសួន

លោក ឡោ ជុនធី

លោក នី ចាន់ឌី

លោក គង់ ពិសី

លោកស្រី Silke STUDZINSKY

លោក យុង ផានិត

**សហមេធាវីការពារក្តី**

លោក ស សូវ៉ាន

លោក Jacques VERGÈS

អង្គបុរេជំនុំជម្រះ PRE-TRIAL CHAMBER E.C.C.C * C.E.T.C CHAMBRE PRELIMINAIRE

១. **អង្គបុរេជំនុំជម្រះនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា** (អ.វ.ត.ក) កត់សម្គាល់ឃើញមាន “សារណាបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០០៧” ដែលសហមេធាវីការពារក្តីជនត្រូវចោទបានដាក់នៅថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០០៧ (“បណ្តឹងឧទ្ធរណ៍”)។

២. បន្ទាប់ពីអង្គបុរេជំនុំជម្រះបានចេញដីកាកំណត់ថ្ងៃសវនាការនៅថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៨ សវនាការលើបណ្តឹងឧទ្ធរណ៍បានបើកជាសាធារណៈនៅថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៨ ហើយបន្ទាប់មក សវនាការនេះបានបន្តជាសម្ងាត់។

៣. នៅពេលចាប់ផ្តើមសវនាការជាសម្ងាត់ និងបន្ទាប់ពីការពិភាក្សារបស់អង្គបុរេជំនុំជម្រះលើបញ្ហាផ្សេងៗដែលភាគីបានលើកឡើង ជនត្រូវចោទបានស្នើសុំលើកពេលសវនាការ ដោយសម្អាងថា សហមេធាវីអន្តរជាតិរបស់ខ្លួនបានបដិសេធបន្តធ្វើជាតំណាងរបស់ខ្លួន ពីព្រោះឯកសារទាំងអស់នៅក្នុងសំណុំរឿងមិនមានជាភាសាបារាំង។ ជនត្រូវចោទបានលើកឡើងថា ខ្លួនត្រូវបានដកសិទ្ធិមានមេធាវីតំណាង ដោយសារអវត្តមានមេធាវីមួយរូប ហេតុដូច្នេះហើយ ខ្លួននឹងមិនមានទំនុកចិត្តនៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍នេះឡើយ។

៤. ដោយសារមូលហេតុនៃការបដិសេធរបស់សហមេធាវីអន្តរជាតិ ក្នុងការបន្តធ្វើជាតំណាងការពារក្តី ដែលត្រូវបានយល់ឃើញថា ជាការដកខ្លួនចេញពីសវនាការលើបណ្តឹងឧទ្ធរណ៍ អង្គបុរេជំនុំជម្រះបានអនុញ្ញាតតាមសំណើរបស់ជនត្រូវចោទ ដែលស្នើសុំលើកពេលសវនាការ ដើម្បីការពារសិទ្ធិរបស់គាត់ក្នុងការទទួលបានមេធាវីការពារត្រឹមត្រូវ នៅចំពោះមុខអង្គបុរេជំនុំជម្រះ។

៥. ក្រោយពីការពិចារណាលើកាលៈទេសៈ ដែលជនត្រូវចោទបានស្នើសុំលើកពេលសវនាការ អង្គបុរេជំនុំជម្រះមិនមានជំហរសម្រេចថា តើសវនាការអាចចាប់ផ្តើមវិញនៅពេលណា ប្រសិនបើមិនមានការចង្អុលបញ្ជាក់ពីមេធាវីការពារក្តី។ អង្គបុរេជំនុំជម្រះបានសម្រេចលើកពេលសវនាការទៅថ្ងៃក្រោយ “ដោយធ្វើការជូនដំណឹងតាមក្រោយ”[១] ដើម្បីទុកពេលវេលាឱ្យសហមេធាវីការពារក្តីរៀបចំខ្លួនដើម្បីជាផលប្រយោជន៍ចំពោះកូនក្តីរបស់គេ។

---

[១] សេចក្តីសម្រេចលើសំណើសុំពន្យារពេលសវនាការលើបណ្តឹងឧទ្ធរណ៍ប្រឆាំងចំពោះដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០០៨ C26/I/25។

ហើយអង្គបុរេជំនុំជម្រះទុកលទ្ធភាពឱ្យសហមេធាវីការពារក្តីជម្រាបមកអង្គបុរេជំនុំជម្រះ អំពីការត្រៀមខ្លួនរួចរាល់របស់ខ្លួនក្នុងការបន្តសវនាការ។

៦. អង្គបុរេជំនុំជម្រះរំលឹកជនត្រូវចោទ និងសហមេធាវីការពារក្តីរបស់ខ្លួនថា មកទល់ពេលនេះ ការលើកពេលសវនាការនេះមានរយៈពេលជិតបួន(៤)ខែហើយ។ អង្គបុរេជំនុំជម្រះមិនទាន់ទទួលបានការជូនដំណឹងណាមួយ អំពីការត្រៀមខ្លួនរួចរាល់ក្នុងការបន្តសវនាការ ឬក៏អំពីបំណងរបស់ខ្លួនចង់ឱ្យអង្គបុរេជំនុំជម្រះធ្វើការសម្រេច ដោយមិនចាំបាច់បើកសវនាការជេញជោល ឬក៏ផ្តល់ព័ត៌មានផ្សេងៗទៀតចំពោះបណ្តឹងឧទ្ធរណ៍នេះឡើយ។

## ហេតុដូច្នេះ អង្គបុរេជំនុំជម្រះបង្គាប់:

ជនត្រូវចោទ និង/ឬក៏ សហមេធាវីការពារក្តីរបស់ខ្លួន បង្ហាញជំហររបស់ខ្លួនចំពោះបណ្តឹងឧទ្ធរណ៍នេះ ក្នុងរយៈពេល **ប្រាំពីរ (៧)ថ្ងៃ** គិតចាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់នេះ។ ✓

ភ្នំពេញ ថ្ងៃទី១៥ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER CHAMBRE PRÉLIMINAIRE * ECCC * CETC

**ប្រាក់ គឹមសាន**